# ព្រះរាជក្រម

នស/រកម/១២០៤/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/១៩៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០០៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង

# ឆ្នាំ ២០០៥

# ជំពូកទី ១

## ចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ២០០៥ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និង ចំណូលនានា ព្រមទាំងផ្ញើឱ្យសំរេចនូវអំណោយ មូលនិធិឧបត្ថម្ភ-ភាគនិងធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង “ក” ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន.......................................................................៣.១៦៨.៦០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត.......................................................................២.២៨២.៦០០ លានរៀល
- ចំណូលជាមូលធន.......................................................................៨៨៦.០០០ លានរៀល
  + ចំណូលជាមូលធនក្នុងប្រទេស.......................................១៦.០០០ លានរៀល
  + ចំណូលជាមូលធនក្រៅប្រទេស.......................................៨៧០.០០០ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវបានកំណត់ស្មើនឹង.......................................៣.១៦៨.៦០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.......................................................................១.៩៨៣.៦០០ លានរៀល
- ចំណាយជាមូលធន.......................................................................១.១៨៥.០០០ លានរៀល
  + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស.....៣៨៥.០០០ លានរៀល
    + ដោយមូលនិធិថវិកា.......................................................២៦៥.០០០ លានរៀល
    + ដោយមូលនិធិក្រៅប្រទេសដែលម្ចាស់ផ្តល់អំណោយបានយល់ព្រមជាមុន.......................................................................១២០.០០០ លានរៀល
  + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលអនុវត្តក្រៅរតនាគារជាតិ[១].......................................៧៥០.០០០ លានរៀល
  + ចំណាយរំលស់បំណុល.......................................................៩០.០០១ លានរៀល

---

[១] វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ហើយចំនួនទឹកប្រាក់នេះមិនឆ្លងកាត់រតនាគារទេ ។

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកាសំរាប់ចំណាយចរន្តរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវបានកំណត់ស្មើនឹង........................................ ១.៩៨៣.៦០០លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង ទៅតាមប្រភេទនៃថវិកាដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសំរាប់ការគ្រប់គ្រងពីឆ្នាំ២០០៥ ដល់ ២០០៧ ត្រូវបានកំណត់ស្មើនឹង........................................ ៥.១០៣.៨៧៥ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគំរោងនិងតាមឆ្នាំដូចមានចែងក្នុងតារាង "គ$_១$-គ$_២$-គ$_៣$" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវបានកំណត់ដូចតទៅ ៖

- ឥណទានភ្ជាប់សន្យា........................................ ១.៦០២.១០០ លានរៀល
- ឥណទានទូទាត់........................................ ១.១៨៥.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ៖

- ឥណទានភ្ជាប់សន្យា........................................ ៣៨៥.០០០ លានរៀល
- ឥណទានទូទាត់........................................ ៣៨៥.០០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ :

- ឥណទានភ្ជាប់សន្យា........................................ ១.១៦៧.១០០ លានរៀល
- ឥណទានទូទាត់........................................ ៧៥០.០០០ លានរៀល

គ. ការវិលសំបិណ្ឌសាធារណៈ ៖

- ឥណទានភ្ជាប់សន្យា........................................ ៥០.០០០ លានរៀល
- ឥណទានទូទាត់........................................ ៥០.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង តាមជំពូកថវិកា ដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## ជំពូកទី ២

## លក្ខខណ្ឌតុល្យភាពនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ៦.-**

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលបានរៀបចំឡើងដោយតារាង "ក" ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង "ខ" ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចតទៅ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+) ឱនភាព (-) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ២.២៩៨.៦០០ | |
| I.១. ចំណូលចរន្ត | ២.២៨២.៦០០ | |
| I.២. ចំណូលជាមូលធនក្នុងប្រទេស | ១៦.០០០ | |
| II. សរុបចំណាយថវិកា | ៣.០៧៨.៦០០ | |
| II.១. ចំណាយចរន្ត | ១.៩៨៣.៦០០ | |
| II.២. ចំណាយជាមូលធន[២] | ១.០៩៥.០០០ | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣៤៥.០០០ | |
| + ដោយមូលនិធិថវិកា | ២២៥.០០០ | |
| គំរោងវិនិយោគ (សាងសង់ - ទិញសំភារៈ) | ១៤៥.០០០ | |
| បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៨០.០០០ | |
| + ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ[៣] | ១២០.០០០ | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧៥០.០០០ | |
| អតិរេកនៃថវិកាចរន្ត (I.១ -II.១ ) | | +២៩៩.០០០ |
| ឱនភាពសរុបនៃថវិកាទូទៅ (I-II ) | | -៧៨០.០០០ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៧៨០.០០០ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៧៨០.០០០ |
| - ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | +១២០.០០០ |
| - ជំនួយគំរោងការ | | +៧៥០.០០០ |
| - ការរំលស់បំណុល | | -៩០.០០០ |
| ២. ហិរញ្ញប្បទានធនាគារជាតិ | | ០ |

[២] មិនគិតការរំលស់បំណុល ៩០.០០០ លានរៀល ដែលមានកំណត់នៅក្នុងសារប័ត្រ III (ហិរញ្ញប្បទាននៃឱនភាព )

[៣] គំរោងទាំងអស់ត្រូវសុំការយល់ព្រមចំណាយពីអ្នកផ្តល់ជំនួយជាមុន ។